រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០៥៤/១៦ អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា ឆ្នាំ២០១៦
## និងទិសដៅការងារ ខែសីហា ឆ្នាំ២០១៦

(ពីថ្ងៃទី២៦/០៦/២០១៦ - ២៥/០៧/២០១៦)

យោងតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែមិថុនា ឆ្នាំ២០១៦ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលដៅចូលរួមចំណែកអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពជូនប្រជាពលរដ្ឋ ។ តាមរយៈ ការអនុវត្តផែនការសកម្មភាពនៃទិសដៅការងារខាងលើ នៅក្នុងខែកក្កដានេះ យើងបានធ្វើការកត់សម្គាល់ទៅលើសភាពការណ៍ និងអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែកក្កដានេះ សកម្មភាពដឹកជញ្ជូនគ្រឿងញៀនពីតំបន់ត្រីកោណមាស ឆ្លងកាត់តាមប្រទេសឡាវ ចូលមកកម្ពុជា នៅតែបន្តកើតមាននៅតាមបណ្តាច្រករបៀងព្រំដែននៃបណ្តាខេត្តនៅភាគឦសាន ។ ជាក់ស្តែង កម្លាំងរបស់ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ និង ខេត្តស្ទឹងត្រែង បង្ក្រាបបាន ០២ ករណីធំៗ ហើយកម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀនក៏បង្ក្រាបបាន ០១ ករណីធំផងដែរ នៅរាជធានីភ្នំពេញ (មុំមន្ទីរពេទ្យព្រះកេតុមាលា) ដោយបានចាប់យកមេតំហ្វេតាមីន ICE និង WY ប្រមាណជាង ៥ គីឡូក្រាម ស្មើនឹង ៥២ % នៃចំនួនមេតំហ្វេតាមីន ICE និង WY ដែលបានចាប់យកក្នុងខែកក្កដានេះ ។ បើប្រៀបធៀបទៅនឹងខែមិថុនា បទល្មើសគ្រឿងញៀនដែលបង្ក្រាបបានក្នុងខែកក្កដានេះ មានការថយចុះ [1] ប៉ុន្តែលទ្ធផលនៃការបង្ក្រាបបានចំករណីធំៗ ព្រមទាំងចាប់បានចំក្រុមមេខ្លោងសំខាន់ៗ ។

ក្រៅពីនេះ ទាំងសមត្ថកិច្ចនគរបាល ក៏ដូចជាកងរាជអាវុធហត្ថ នៅតាមរាជធានី-ខេត្ត បានយកចិត្តទុកដាក់បង្ក្រាបបទល្មើសគ្រឿងញៀនយ៉ាងសកម្ម ទាំងបទល្មើសជួញដូរគ្រឿងញៀនក្នុងរូបភាពតូចតាច ទាំងបទល្មើសប្រើប្រាស់គ្រឿងញៀន ។

1) លទ្ធផលប្រៀបធៀបបទល្មើសគ្រឿងញៀន រវាងខែកក្កដា ជាមួយខែមិថុនា ឆ្នាំ២០១៦ មាននៅទំព័រទី៧ នៃរបាយការណ៍



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០៥៤/១៦ អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា ឆ្នាំ២០១៦
## និងទិសដៅការងារ ខែសីហា ឆ្នាំ២០១៦
(ពីថ្ងៃទី២៦/០៦/២០១៦ - ២៥/០៧/២០១៦)

យោងតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែមិថុនា ឆ្នាំ២០១៦ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលដៅចូលរួមចំណែកអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពជូនប្រជាពលរដ្ឋ ។ តាមរយៈ ការអនុវត្តផែនការ សកម្មភាពនៃទិសដៅការងារខាងលើ នៅក្នុងខែកក្កដានេះ យើងបានធ្វើការកត់សម្គាល់ទៅលើសភាពការណ៍ និង អនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែកក្កដានេះ សកម្មភាពដឹកជញ្ជូនគ្រឿងញៀនពីតំបន់ត្រីកោណមាស ឆ្លងកាត់តាមប្រទេសឡាវ ចូលមក កម្ពុជា នៅតែបន្តកើតមាននៅតាមបណ្តាច្រករបៀងព្រំដែននៃបណ្តាខេត្តនៅភាគឦសាន ។ ជាក់ស្តែង កម្លាំងរបស់ ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ និង ខេត្តស្ទឹងត្រែង បង្ក្រាបបាន ០២ ករណីធំៗ ហើយកម្លាំងរបស់មន្ទីរប្រឆាំង គ្រឿងញៀនក៏បង្ក្រាបបាន ០១ ករណីធំផងដែរ នៅរាជធានីភ្នំពេញ (មុំមន្ទីរពេទ្យព្រះកេតុមាលា) ដោយបានចាប់ យកមេតំហ្វេតាមីន ICE និង WY ប្រមាណជាង ៥ គីឡូក្រាម ស្មើនឹង ៥២ % នៃចំនួនមេតំហ្វេតាមីន ICE និង WY ដែលបានចាប់យកក្នុងខែកក្កដានេះ ។ បើប្រៀបធៀបទៅនឹងខែមិថុនា បទល្មើសគ្រឿងញៀនដែលបង្ក្រាបបានក្នុង ខែកក្កដានេះ មានការថយចុះ [1] ប៉ុន្តែលទ្ធផលនៃការបង្ក្រាបបានចំករណីធំៗ ព្រមទាំងចាប់បានចំក្រុមមេខ្លោង សំខាន់ៗ ។

ក្រៅពីនេះ ទាំងសមត្ថកិច្ចនគរបាល ក៏ដូចជាកងរាជអាវុធហត្ថ នៅតាមរាជធានី-ខេត្ត បានយកចិត្តទុកដាក់ បង្ក្រាបបទល្មើសគ្រឿងញៀនយ៉ាងសកម្ម ទាំងបទល្មើសជួញដូរគ្រឿងញៀនក្នុងរូបភាពតូចតាច ទាំងបទល្មើសប្រើ ប្រាស់គ្រឿងញៀន ។

1) លទ្ធផលប្រៀបធៀបបទល្មើសគ្រឿងញៀន រវាងខែកក្កដា ជាមួយខែមិថុនា ឆ្នាំ២០១៦ មាននៅទំព័រទី៧ នៃរបាយការណ៍



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

## II. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ បាន ៖

• ដឹកនាំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន " ២៦ មិថុនា ២០១៦ " នៅខេត្តបាត់ដំបង កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ ដែលមានការចូលរួមពីមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ក្រុមកាយឫទ្ធិ ប្រជាពលរដ្ឋ ម្ចាស់ផ្ទះសំណាក់ សណ្ឋាគារ ម្ចាស់អាជីវកម្មកម្សាន្ត ។ល។ និង ។ល។

• បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងពិធីជួបសំណេះសំណាល ជាមួយសិស្សានុសិស្ស និងប្រជាពលរដ្ឋ នៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៦ ដែលសរុបមានមហាជនចូលរួមប្រមាណ ៦.៨៤៨ នាក់

• ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ បានដឹកនាំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន " ២៦ មិថុនា ២០១៦ " នៅខេត្តតាកែវ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ ដែលមានការចូលរួមពីមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ក្រុមកាយឫទ្ធិ ប្រជាពលរដ្ឋ ម្ចាស់ផ្ទះសំណាក់ សណ្ឋាគារ ម្ចាស់អាជីវកម្មកម្សាន្ត ។ល។ និង ។ល។ ដែលមានមហាជនចូលរួមប្រមាណ ២.៣៣៣ នាក់

- ក្រៅពីការងារខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ បានបន្តដឹកនាំនិងណែនាំលើការងារជាគោលសំខាន់ៗ សម្រាប់អនុវត្តក្នុងខែកក្កដានេះ និងការងារមួយចំនួនជាទិសដៅសម្រាប់អនុវត្តបន្តក្នុងខែសីហា មានដូចតទៅ ៖

**១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តដឹកនាំការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "២៦ មិថុនា ២០១៦" ចំពោះខេត្តណាដែលមិនទាន់បានប្រារព្ធ ។ ជាមួយនេះត្រូវបន្តការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមតំបន់មិនរៀបរយ, រោងចក្រសហគ្រាស, តំបន់ផ្ទះកម្មករជួលស្នាក់នៅ, តំបន់គោលដៅទេសចរណ៍, ព្រមទាំងបង្កើនការបណ្តុះបណ្តាលក្រុមជនបង្គោល, រៀបចំក្រុមការងារចងក្រងបទពិសោធន៍ ជាឯកសារសម្រាប់អប់រំបង្ការការប្រើបំពានគ្រឿងញៀននៅតាមសាលារៀន និងបន្តកម្មវិធីប្រឡងគូរគំនូរអប់រំពីបញ្ហាគ្រឿងញៀន ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទា ត្រូវបន្តរៀបចំបង្កើតមណ្ឌលសុខភាពនៅក្នុងមណ្ឌលឱកាសខ្ញុំ, ប៉ុស្តិ៍សុខភាពនៅតាមមន្ទីរអប់រំកែប្រែ-ពន្ធនាគារ និងពង្រឹងសមត្ថភាព គុណភាពការងារព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលបណ្តោះអាសន្ន ព្រមទាំងជំរុញការរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន និងប្រកាសរួមស្តីពីការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ឱ្យបានឆាប់រហ័ស ។ ជាមួយនេះត្រូវចុះពិនិត្យជាក់ស្តែងពាក់ព័ន្ធនឹងការដំឡើងប៉ាណូ ផ្សព្វផ្សាយពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយឥតគិតថ្លៃ នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ក្នុងរាជធានីភ្នំពេញកន្លងមក ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តបើកវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) ប្រព័ន្ធអេឡិចត្រូនិច (E-Learning), មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទនៅតាមបណ្តាខេត្ត, មន្ត្រីយោធានៅតាមភូមិភាគ ព្រមទាំងបន្តបណ្តុះបណ្តាលដល់ក្រុមយោធាបង្គោល នៃកង

យោធពលខេមរភូមិន្ទ និងបន្តពង្រឹងយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ត្រូវរៀបចំផែនការ និងយន្តការជាក់លាក់សម្រាប់គ្រប់គ្រង ត្រួតពិនិត្យតាមដានលើការនាំចូល និងការប្រើប្រាស់សារធាតុគីមីផ្សំ និងបន្តប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មីដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ព្រមទាំងត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីការធ្វើតេស្តគ្រឿងញៀន និងសារធាតុគីមីផ្សំ, ការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** ជារួម ត្រូវបន្តអនុវត្តនូវរាល់កិច្ចការ ដែលបានព្រមព្រៀងគ្នាកន្លងមក ជាមួយភាគីថៃ ឡាវ និងវៀតណាម ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ។ ជាមួយនេះ ត្រូវត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់កិច្ចប្រជុំទ្វេភាគី ត្រីភាគី កម្ពុជា វៀតណាម ឡាវ លើកទី១៦ ដែលនឹងត្រូវរៀបចំនៅកម្ពុជា ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** ត្រូវបន្តអនុវត្តនូវរាល់ខ្លឹមសារនៃកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយអង្គការ UNODC បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ ជាពិសេសគម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project), គម្រោងពង្រឹងប្រសិទ្ធភាពការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងត្រូវធ្វើការបូកសរុប ដកពិសោធន៍ ពីលទ្ធផលដែលបានចុះជួយពង្រឹងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក្នុងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងជំរុញដល់រាជធានី-ខេត្ត ឱ្យរៀបចំបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនដល់ថ្នាក់ខ័ណ្ឌ ក្រុង ស្រុក សង្កាត់ ឃុំ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

តាមទិសដៅដែលបានដាក់ចេញកាលពីខែមិថុនា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១** ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន ៖

- សហការជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិ ផលិតនូវបទយកការណ៍ខ្លីចំនួន២ ក្រោមប្រធានបទ " **ការថែទាំ ព្យាបាល ការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅតាមសហគមន៍** " និង " **ការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន** " និង វេទិកាតុមូលក្រោមប្រធានបទ " **រួមគ្នាប្រយុទ្ធប្រឆាំងគ្រឿងញៀន** "
- អញ្ជើញតំណាងគណៈកម្មាធិការត្រួតពិនិត្យ គ្រឿងញៀនខេត្តសៀមរាប ដើម្បីផ្តល់បទសម្ភាសន៍ក្រោមប្រធានបទ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនលើទឹកដីទេសចរណ៍ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦
- អញ្ជើញនាយកវិទ្យាល័យបាក់ទូក និង វិទ្យាល័យបឹងត្របែក ដើម្បីចូលរួមផ្តល់កិច្ចសម្ភាសន៍នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ តាមកម្មវិធីនិងប្រធានបទ ដូចតទៅ ៖
  - កម្មវិធីព័ត៌មានពេលថ្ងៃ ស្តីពីសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងវិទ្យាល័យបាក់ទូក

• កម្មវិធីព័ត៌មានពេលល្ងាច ស្តីពីសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់ នៃគ្រឿងញៀន នៅក្នុងវិទ្យាល័យបឹងត្របែក ។

**១.២ ការងារអប់រំតាមសហគមន៍ ៖** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៣ បានចុះអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមមូលដ្ឋានរបស់ខ្លួន (ឈ្មោះក្រសួង-ស្ថាប័ន-ខេត្ត, វេទិកា និងខ្លឹមសារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ និងនៅតាមសហគមន៍ មាននៅទំព័រទី០១-០២ នៃតារាងឧបសម្ព័ន្ធ) ។ លទ្ធផលជារួម មហាជនដែលបានទៅទទួលសារអប់រំមានប្រមាណ **៥០.៨៣៩** នាក់ និង សិស្សបង្គោលប្រចាំថ្នាក់ប្រមាណ ៨៦២ នាក់ ។

ក្នុងនោះ សកម្មភាពការងារអប់រំដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានអនុវត្តមានដូចខាងក្រោម ៖

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តដឹកនាំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅខេត្តកំពត, ខេត្តកណ្តាល, ខេត្តកំពង់ចាម , ខេត្តស្វាយរៀង, ខេត្តស្ទឹងត្រែង, ខេត្តបន្ទាយមានជ័យ, ខេត្តសៀមរាប និងខេត្តព្រះសីហនុ ដែលមានមហាជនចូលរួមប្រមាណ ១១.៧៣៣ នាក់

- បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ចាប់ពីថ្ងៃទី១៩-២៥ ខែកក្កដា ឆ្នាំ ២០១៦ នៅវិទ្យាល័យភ្នំពេញថ្មី វិទ្យាល័យវត្តកោះ វិទ្យាល័យវត្តភ្នំ វិទ្យាល័យបាក់ទូក វិទ្យាល័យឫស្សីកែវ អនុវិទ្យាល័យវត្តទួលសុវណ្ណារាម វិទ្យាល័យចម្រើនរដ្ឋ វិទ្យាល័យចម្រើនជាតិ វិទ្យាល័យព្រែកលៀប វិទ្យាល័យបាក់ខែង និងវិទ្យាល័យជ្រោយចង្វារ (លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ប្រមាណ ២២.៨២០ នាក់ និងសិស្សបង្គោលប្រចាំថ្នាក់ ៨៦២ នាក់)

- រៀបចំពិធីប្រកួតផ្តាច់ព្រ័ត្រ ការគូរគំនូរអប់រំពីបញ្ហាគ្រឿងញៀន នៅវិទ្យាល័យបញ្ញាសាស្ត្រ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ដោយបានប្រកាសលទ្ធផល និងចែករង្វាន់ប្រកួតផ្តាច់ព្រ័ត្រដល់ក្រុមជ័យលាភីលេខ១ លេខ២ និងលេខ៣ ចំនួន ៩៣ នាក់ រួមទាំងការផ្តល់ជូននូវប័ណ្ណសរសើរ និងលិខិតសរសើរផងដែរ

- ចូលរួមធ្វើបទបង្ហាញស្តីពីបញ្ហាគ្រឿងញៀននៅក្នុងសិក្ខាសាលាពង្រឹងសមត្ថភាព ស្តីពីលក្ខខណ្ឌការងារ វិជានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ផ្នែកសេវាកម្សាន្ត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី២៨-២៩ ខែមិថុនា ឆ្នាំ២០១៦ នៅខេត្តសៀមរាប

- បានចូលរួមធ្វើបទឧទ្ទេសនាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់ នៃគ្រឿងញៀន នៅក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីនៃកងយោធពលខេមរភូមិន្ទ រួមមាន ៖

  • មន្ត្រីយោធានៅតំបន់ប្រតិបត្តិការសឹករង ចំណុះយោធភូមិភាគ ៥ (ខេត្តពោធិ៍សាត់, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន) ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ ( ៦០២ នាក់)
  • វគ្គបំប៉ននាយទាហានកងរាជអាវុធហត្ថថ្នាក់ឧត្តមសេនីយ៍ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ (២៩ នាក់)
  • វគ្គបំប៉ននាយទាហាន កងរាជអាវុធហត្ថថ្នាក់វរសេនីយ៍ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ (៥៨ នាក់)

- បានចូលរួមជាវាគ្មិនផ្សព្វផ្សាយអប់រំពីសភាពការណ៍, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំនួន ៣០០ នាក់ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦

- ចូលរួមកិច្ចប្រជុំបូកសរុបការងារផ្សព្វផ្សាយ បង្ការការប្រើបំពានគ្រឿងញៀន និងគ្រឿងស្រវឹង ដើម្បីសុវត្ថិភាពសហគមន៍មូលដ្ឋាន កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ នៅស្រុកកងមាស ខេត្តកំពង់ចាម (អ្នកចូលរួម ៦០ នាក់)

- បាន និងកំពុងបន្តដំណើរការដំឡើងផ្ទាំងប៉ាណូអប់រំពីបញ្ហាគ្រឿងញៀន សម្រាប់ដាក់នៅតាមតំបន់ព្រំដែនកម្ពុជា-ឡាវ

- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែ មិថុនា ឆ្នាំ២០១៦ មានការចូលអានប្រមាណ **៣៨.៣៣៦** ដង ។

ដោយឡែកនៅក្រៅប្រទេស អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចាត់បញ្ជូនមន្ត្រីជំនាញចំនួន ០៣ រូប (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប) ទៅចូលរួម កិច្ចពិភាក្សាពីការបង្ការការប្រើបំពានគ្រឿងញៀនដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន កាលពីថ្ងៃទី១៣-១៧ ខែកក្កដា ឆ្នាំ២០១៦ នៅប្រទេសថៃ ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ៖

២.១.១. បានចូលរួមកិច្ចសន្ទនាស្តីពីយុទ្ធនាការ " គាំទ្រ ! បញ្ឈប់ទណ្ឌកម្ម " កាលពីថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១៦ ដែលរៀបចំដោយអង្គការខាន់ណា និងអង្គការដៃគូ ក្នុងគោលបំណងឆ្លុះបញ្ចាំងពីលទ្ធផលនៃការគាំទ្រសកម្មភាពដែលបានអនុវត្តកន្លងមក និងស្វែងរកការគាំទ្របន្ថែមទៀត ដើម្បីលើកកម្ពស់លើការងារកាត់បន្ថយគ្រោះថ្នាក់ដល់អ្នកប្រើបំពានគ្រឿងញៀន ។

២.១.២. បានចូលរួមក្នុងវេទិកាពិភាក្សារវាងដៃគូពាក់ព័ន្ធជាមួយនឹងតំណាងក្រុមប្រឈមមុខខ្ពស់ និងអ្នកផ្ទុកមេរោគអេដស៍ ដើម្បីពង្រឹងបណ្តាញនៃក្រុមទាំងនោះ នៅតាមស្រុកប្រតិបត្តិទាំង៣៣ ដែលប្រឈមមុខខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ (អ្នកចូលរួម ៥៩ នាក់)

២.១.៣. បានចូលរួមជាអធិបតីនៅក្នុងពិធីបិទបញ្ចប់សកម្មភាពការសិក្សាស្រាវជ្រាវ ស្តីពីការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ និងគ្រឿងញៀន (CIPI) ដែលបានអនុវត្តនៅខេត្តកណ្តាល ដែលកម្មវិធីនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ នៅខេត្តកណ្តាល (អ្នកចូលរួម ៣០ នាក់) ។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

២.២.១. ក្រុមលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទា បានបន្តចុះពង្រឹងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ឯកជន មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងមណ្ឌលសំចតរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦ នៅតាមរាជធានី-ខេត្តមួយចំនួន ។

២.២.២. បានប្រជុំគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីពិនិត្យលើសេចក្តីព្រាងសេចក្តីណែនាំសម្រាប់ការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្ន និងពិនិត្យលើសេចក្តីព្រាងប្រកាសរួមរវាងក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។ **ដោយឡែក នៅក្រៅប្រទេស ៖**

២.២.៣. បានចាត់បញ្ជូនមន្ត្រីជំនាញ ០៣ រូប (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប) ទៅចូលរួមសន្និសីទអាស៊ាន លើកទី៤ ឆ្នាំ២០១៦ ស្តីពីការរួមបញ្ចូលគ្នានូវវិធីសាស្ត្រដ៏ល្អ នៃការងារព្យាបាលអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៣.១. បានរៀបចំពិធីផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍ ស្តីពីការរឹបអូសទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន (ការរឹបអូសទ្រព្យនៅប្រទេសថៃ) ដែលធ្វើបទឧទ្ទេសនាមដោយក្រុមមន្ត្រីជំនាញនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ដល់មន្ត្រីអនុវត្តន៍ច្បាប់កម្ពុជាប្រមាណ ១១៥ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ២០ នាក់) ។

៣.២. បានចុះផ្សព្វផ្សាយសភាពការណ៍ កិច្ចប្រតិបត្តិការ និងពង្រឹងការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីពាក់ព័ន្ធរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តព្រះវិហារ (មន្ត្រីចូលរួម ៥៦ នាក់) និងខេត្តឧត្តរមានជ័យ កាល ពីថ្ងៃទី១៣-១៤ ខែកក្កដា ឆ្នាំ២០១៦ (មន្ត្រីចូលរួម ៤២ នាក់) សរុប ៩៨ នាក់ ។

៣.៣. បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ១២ រូប ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី៥/ឆ្នាំ២០១៦ ពីថ្ងៃទី១៨-២២ ខែកក្កដា ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ។

៣.៤. បានរៀបចំបញ្ជីទ្រព្យសម្បត្តិ ជាកម្មវត្ថុនៃការរឹបអូសវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលនគរបាលនៃមន្ទីរប្រឆាំងគ្រឿងញៀន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បង្ក្រាបបានកន្លងមក ។

**ដោយឡែក នៅក្រៅប្រទេស ៖**

៣.១. បានចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប ទៅចូលរួមសិក្ខាសាលា ស្តីពីប្រតិបត្តិការប្រព័ន្ធត្រួតពិនិត្យគ្រឿងញៀនអាស៊ាន លើកទី២ (ASEAN Drug Monitoring Network Operational Workshop II) កាលពីថ្ងៃទី២៨-៣០ ខែមិថុនា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៣.២. បានចាត់បញ្ជូនមន្ត្រី ៣២ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៥ នាក់) ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការបង្កើនកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន នៅតំបន់ព្រំដែនកម្ពុជា-ថៃ កាលពីថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៦ ។

៣.៣. បានចាត់បញ្ជូនមន្ត្រីចំនួន ២០ រូប (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៨ រូប) ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មគ្រឿងញៀន និងការវិភាគគ្រឿងញៀន កាលពីថ្ងៃទី០៣-០៨ ខែកក្កដា ឆ្នាំ២០១៦ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ។

៣.៤. បានចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ចំនួន ០២ រូប ទៅ ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលអាជ្ញាធរមានសមត្ថកិច្ចអនុវត្តន៍ច្បាប់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ី-ប៉ាស៊ីហ្វិក (Training Seminar for Competent National Authorities in the South and East Asia and the Pacific Regions) កាលពីថ្ងៃទី ១២-១៥ ខែកក្កដា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៣.៥. បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ០១ រូប និងមន្ត្រីជំនាញរបស់ក្រសួងពាក់ព័ន្ធ ០២ រូប ទៅចូលរួមកិច្ចប្រជុំ លើកទី១ នៃក្រុមការងារអាស៊ាន ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមកំពង់ផែសមុទ្រ កាលពីថ្ងៃទី ១៩ ដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ នៅប្រទេសឥណ្ឌូនេស៊ី ។

## ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- **បទល្មើសគ្រឿងញៀន** សរុប **៣៦៦** ករណី លើ ៤០៧ ករណី នៃខែមិថុនា ឆ្នាំ២០១៦[2]

- **ជនសង្ស័យ** ឃាត់ខ្លួន សរុប **៨៤៤** នាក់ (ស្រី ៧៨ នាក់) លើ ៩៣១ នាក់ នៃខែមិថុនា ឆ្នាំ២០១៦

- ក្នុងបទល្មើសគ្រឿងញៀនទាំង ៣៦៦ ករណី និងជនសង្ស័យទាំង ៨៤៤ នាក់ ខាងលើគឺ ៖

- បទល្មើសគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចនគរបាល ២៧៣** ករណី, ជនសង្ស័យ **៥៧១** នាក់ (ស្រី ៥៣ នាក់)
- បទល្មើសគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ ៩៣** ករណី, ជនសង្ស័យ **២៧៣** នាក់ (ស្រី ២៥ នាក់)

- ក្នុងចំនួនជនសង្ស័យ ៨៤៤ នាក់ ខាងលើមាន ០៤ សញ្ជាតិគឺ ខ្មែរ ៨៣០ នាក់ (ស្រី ៧៥ នាក់), វៀតណាម ១០ នាក់ (ស្រី ០៣ នាក់), ឡាវ ០៣ នាក់ (ប្រុស), អាមេរិក ០១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត

- **វត្ថុតាងគ្រឿងញៀនចាប់យក ៖** មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៨គ.ក្រ ៨៣៦ក្រាម ៨៤ មេតំហ្វេតាមីនគ្រាប់ WY ១ គ.ក្រ ២០២ ក្រាម ៥៣, កេតាមីន ០,៤៨ ក្រាម, កញ្ឆាក្រៀម ១០១,១០ ក្រាម

**(សរុប គ្រឿងញៀនទាំងអស់មានចំនួន ១០ គ.ក្រ ១៤០ ក្រាម ៩៥)**

- **ទ្រព្យសម្បត្តិសំខាន់ៗ** ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន ៖ រថយន្ត ៦ គ្រឿង ម៉ូតូ ១៥១ គ្រឿង, ប្រាក់កម្ពុជា ៤.៦៧០.៥០០ រៀល, ប្រាក់អាមេរិក ៣.១២៧ ដុល្លារ

- ជនសង្ស័យចាប់តាមដីកា មាន ២៧ ដីកា = ជនសង្ស័យ ២៤ នាក់ (ស្រី ០៣ នាក់) ។

## ៣.៣. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

សំណាកសង្ស័យជាគ្រឿងញៀនដែលបានធ្វើកោសល្យវិច័យក្នុងខែកក្កដា ឆ្នាំ២០១៦ សរុប ១៩៦ ករណី = ២១៧ សំណាក ក្នុងនោះ ៖

- **សំណាក វិជ្ជមានសារធាតុញៀន** មាន ១៩២ ករណី = ២១០ សំណាក (៩៦,៧៥ %)គឺ ៖
  - មេតំហ្វេតាមីន ICE ១៧៨ សំណាក = ៨២,០២ %
  - មេតំហ្វេតាមីន WY ២០ សំណាក = ៩,២១ %
  - ហេរ៉ូអ៊ីន ៣ សំណាក = ១,៣៨ %
  - កេតាមីន ០៥ សំណាក = ២,៣០ %
  - កញ្ឆា ០២ សំណាក = ០,៩២ %
  - MDMA ០២ សំណាក = ០,៩២ %
- **សំណាក អវិជ្ជមានសារធាតុញៀន** ០៤ ករណី = ០៧ សំណាក (៣,២២ %)

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- សារធាតុគីមីផ្សំពាក់ព័ន្ធនឹងតារាងទី IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានអនុញ្ញាតឱ្យនាំចូលនៅក្នុងខែកក្កដា ឆ្នាំ២០១៦នេះ សរុបមាន **១.៦៩៨.៩៦២** គ.ក្រ និង ៧២ លីត្រ ក្នុងនោះ ៖

- មានបទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចំនួន ១.២៧៩.១៤២ គ.ក្រ និង ៧២ លីត្រ
- មានលិខិតអនុញ្ញាតឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំនួន ៤១៩.៨២០ គ.ក្រ

[2] តួលេខបទល្មើស វត្ថុតាងគ្រឿងញៀន ទ្រព្យសម្បត្តិប្រចាំខែកក្កដា និងឆ្នាំ២០១៦ មានចាប់ពីទំព័រទី១១ ដល់ទំព័រទី២៧

- សារធាតុក្នុងទម្រង់ជាវត្ថុធាតុដើម ដែលមានអាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រសួងសុខាភិបាល ចំនួន ១០០ គ.ក្រ និង ក្នុងទម្រង់ជាសារធាតុញៀនផ្ទុកក្នុងឱសថ មាន ៣ គ.ក្រ ៣០០ ក្រាម

ដោយឡែក សារធាតុញៀនដែលមានចែងនៅក្នុងតារាងទី២ និងទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាននៅទំព័រទី៣១-៣២ នៃតារាងឧបសម្ព័ន្ធ ។

- បានចាត់មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប ទៅចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងសារធាតុគីមីផ្សំ និងសារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ កាលពីថ្ងៃទី១២-១៥ ខែកក្កដា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ (រៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ INCB)

- បានសហការជាមួយក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ បន្តធ្វើការកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. បានរៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃ លើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី២៣-២៥ ខែកក្កដា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ។

៥.២. បាននិងកំពុងបន្តកិច្ចសហការជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) រៀបចំឯកសារពាក់ព័ន្ធ សម្រាប់ការទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការវិភាគគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ ។

៥.៣. បានចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីធ្វើវឌ្ឍនភាពរបាយការណ៍ជូនសម្តេចតេជោនាយករដ្ឋមន្ត្រី និងត្រៀមរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំគណៈកម្មាធិការចម្រុះសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ លើកទី១០ (JC) នៅប្រទេសថៃ ។

៥.៤. បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ០១ រូប ចូលជាសមាជិកគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ។

៥.៥. បានទំនាក់ទំនងជាមួយការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់ប្រទេសវៀតណាម និងត្រៀមឯកសារពាក់ព័ន្ធសម្រាប់ការទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការទាក់ទងនិងការវិភាគ ការស៊ើបអង្កេតបទល្មើសគ្រឿងញៀន។

៥.៦. បានបន្តរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកំណត់ហេតុប្រជុំ JC កម្ពុជា-ឡាវ លើកទី១២ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

៦.១. បានសហការជាមួយអង្គការ UNODC រៀបចំកិច្ចប្រជុំស្តីពីការអនុវត្តច្បាប់គ្រឿងញៀនមហាអនុតំបន់ទន្លេមេគង្គ លើកទី២ កាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ។

៦.២. បានធ្វើការទំនាក់ទំនងនិងរៀបចំឯកសារពាក់ព័ន្ធនឹងវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើតេស្តគ្រឿងញៀន និងសារធាតុគីមីផ្សំ ។

៦.៣. បន្តការទំនាក់ទំនង និងរៀបចំឯកសារពាក់ព័ន្ធ សម្រាប់ការទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន (Control of Drug Offences) នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។

៦.៤. បាននិងកំពុងបន្តការទំនាក់ទំនងជាមួយអគ្គរដ្ឋអាជ្ញាជាន់ខ្ពស់នៃសាធារណរដ្ឋកូរ៉េ ក្នុងការរៀបចំឯក-

សារ សម្រាប់ការទៅចូលរួមសិក្ខាសាលា Pre-Project ស្តីពីការពង្រឹងការិយាល័យទំនាក់ទំនងព្រំដែន (BLOs) តាមដងទន្លេមេគង្គ ។

៦.៥. បាននិងកំពុងរៀបចំឯកសារពាក់ព័ន្ធ សម្រាប់ការទៅចូលរួមសិក្ខាសាលា Global SMART តំបន់ ។

៦.៦. បានទំនាក់ទំនង និងរៀបចំឯកសារពាក់ព័ន្ធ សម្រាប់ការទៅចូលរួមក្នុងកិច្ចប្រជុំស្តីពី សុវត្ថិភាពសហគមន៍អាស៊ានប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ឆ្នាំ២០១៦-២០២៥ ។

៦.៧. បាននិងកំពុងត្រៀមអ្នកជំនាញផ្នែកគ្រឿងញៀន ០១ រូប និងរៀបចំឯកសារពាក់ព័ន្ធនឹងគ្រឿងញៀន រួមមាន ៖ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, អនុស្សរណៈនៃការយោគយល់គ្នា និងរបាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៥ បញ្ជូនទៅស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅទីក្រុងណាននីន សម្រាប់បោះពុម្ពជាភាសាចិន និងភាសាអង់គ្លេស ដើម្បីផ្សព្វផ្សាយក្នុងប្រទេសចិន និងបណ្តាប្រទេសអាស៊ាន ។

### ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. បាននិងកំពុងរៀបចំគណៈកម្មការតាមដាន ការប្រមូល ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

៧.២. បានបន្តការកែសម្រួលសេចក្តីព្រាងផែនការជាតិ ៣ ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧.៣. បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៤. បាននិងកំពុងបន្តការកែសម្រួល សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៧.៥. បាននិងកំពុងរៀបចំសេចក្តីសម្រេចស្តីពីបង្កើតក្រុមការងារ ចុះជួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការកសាងផែនការត្រួតពិនិត្យគ្រឿងញៀនសម្រាប់ថ្នាក់ខណ្ឌ និងសង្កាត់ (ជាពិសេសភូមិត្រពាំងឈូក) ។

**ដោយឡែក ខេត្តមណ្ឌលគិរី** បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆមាសទី១ ឆ្នាំ២០១៦ ដែលមានសមាសភាពចូលរួម ៤៦ នាក់ ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១៦

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

១.១. ត្រៀមចូលរួមផ្សព្វផ្សាយពីសភាពការណ៍គ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន និងការចូលរួមទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ក្នុងវគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយការយល់ដឹងពីការបញ្ជ្រាបយេនឌ័រ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនក្នុងវិស័យទេសចរណ៍ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៦ នៅខេត្តព្រះវិហារ ។

១.២. ត្រៀមចូលរួមជាវាគ្មិននៅក្នុងកម្មវិធី " កិច្ចពិភាក្សា៨នាទី " ក្រោមប្រធានបទស្តីពីស្ថានភាពគ្រឿងញៀននៅកម្ពុជា ដែលរៀបចំដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCiM) សម្រាប់ផ្សាយតាមទូរទស្សន៍អនឡាយវីអូឌី (Voice Of Democracy) www.vodtvnews.com និងទំព័រ facebook VOD ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ។

១.៣. ត្រៀមសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយ

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តបាត់ដំបង នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ។

១.៤. ត្រៀមរៀបចំ និងអញ្ជើញនាយកវិទ្យាល័យបុរី១០០ខ្នង និង សង្កាត់ភ្នំពេញថ្មី វិទ្យាល័យភ្នំពេញ ផ្តល់បទសម្ភាសន៍ នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ក្នុងកម្មវិធី ៖

- ព័ត៌មានពេលថ្ងៃ ក្រោមប្រធានបទស្តីពីសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់ នៃគ្រឿងញៀន នៅក្នុងវិទ្យាល័យបុរី១០០ខ្នង
- ព័ត៌មានពេលរសៀល ក្រោមប្រធានបទស្តីពីការអប់រំ បង្ការ និងដោះស្រាយបញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រសង្កាត់ភ្នំពេញថ្មី
- ព័ត៌មានពេលល្ងាច ក្រោមប្រធានបទស្តីពីសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងវិទ្យាល័យភ្នំពេញថ្មី ។

១.៥. បន្តសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមរោងចក្រ សហគ្រាស តំបន់ផ្ទះកម្មករជួលស្នាក់នៅ ដោយសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

១.៦. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន ។

១.៧. បន្តសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និងបណ្តាក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីកម្សាន្តសប្បាយ និងកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជននានា ។

១.៨. បន្តចុះធ្វើសកម្មភាពអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន នៅតាមសាលារៀន និងគោលដៅងាយកើតមានបទល្មើសគ្រឿងញៀន ។

១.៩. បន្តចលនាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.១០. បន្តការរៀបចំដំឡើងផ្ទាំងប៉ាណូអប់រំពីបញ្ហាគ្រឿងញៀននៅតាមបណ្តាច្រកព្រំដែនកម្ពុជា-ឡាវ ។

១.១១. រៀបចំក្រុមការងារចងក្រងបទពិសោធន៍ និងឯកសារបង្ការការប្រើបំពានគ្រឿងញៀននៅតាមសាលារៀន ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន**

២.១. ត្រៀមចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ ការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងការប្រព្រឹត្តផ្លូវភេទ ក្នុងចំណោមក្រុមភេទទី៣ នៅប្រទេសកម្ពុជា ប្រចាំឆ្នាំ២០១៥ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ។

២.២. ត្រៀមសហការជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) រៀបចំសិក្ខាសាលា កម្ពុជា-ថៃ ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៩-១១ ខែសីហា ឆ្នាំ២០១៦ នៅខេត្តព្រះសីហនុ (មន្ត្រីពាក់ព័ន្ធ ៣៥ នាក់ / មន្ត្រីអគ្គលេខាធិការដ្ឋាន ០៦ នាក់) ។

២.៣. ត្រៀមចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២១-២៦ ខែសីហា ឆ្នាំ២០១៦ នៅប្រទេសវៀតណាម ។

២.៤. ត្រៀមចាត់បញ្ជូនមន្ត្រីពាក់ព័ន្ធ ចំនួន ២០ រូប (មន្ត្រីអគ្គលេខាធិការ ០៣ រូប) ទៅចូលរួមវគ្គបណ្តុះ

បណ្តាលស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២១-២៦ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ។

២.៥. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្មថែមទៀត ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀន បានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាពណាដែលមានទំនុកចិត្ត ។

២.៦. បន្តការកែសម្រួលនិងពង្រឹងសមត្ថភាព គុណភាពនៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៧. ត្រៀមចុះត្រួតពិនិត្យជាក់ស្តែងពាក់ព័ន្ធនឹងការដំឡើងប៉ាណូ ផ្សព្វផ្សាយពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយឥតគិតថ្លៃនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកក្នុងរាជធានីភ្នំពេញ កន្លងមក

២.៨. បន្តការចុះពង្រឹងសេវាព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ឯកជន មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក

២.៩. បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីពង្រឹងយន្តការក្នុងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

### ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

៣.១. បន្តបើកវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី៦/ឆ្នាំ២០១៦ ដល់នគរបាលនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ (ថ្ងៃទី ២៥-២៩ ខែកក្កដា ឆ្នាំ២០១៦) ។

៣.២. ត្រៀមចាត់បញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលា Pre-Project ស្តីពីការពង្រឹងការិយាល័យទំនាក់ទំនងព្រំដែន (BLOs) តាមដងទន្លេមេគង្គ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ នៅប្រទេសថៃ ។

៣.៣. ត្រៀមទៅចូលរួមក្នុងកិច្ចប្រជុំស្តីពី សុវត្ថិភាពសហគមន៍អាស៊ានប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ឆ្នាំ២០១៦-២០២៥ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២១-២៣ ខែសីហា ឆ្នាំ២០១៦ នៅប្រទេសថៃ ។

៣.៤. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន (Control of Drug Offences) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។

៣.៥. ត្រៀមចាត់បញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលា Global SMART តំបន់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ ។

៣.៦. បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែនតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning) ។

៣.៧. ត្រៀមរៀបចំកិច្ចប្រជុំត្រួតពិនិត្យយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

៣.៨. បន្តរៀបចំបញ្ជីទ្រព្យសម្បត្តិ ជាកម្មវត្ថុនៃការរឹបវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលនគរបាលនៃមន្ទីរប្រឆាំងគ្រឿងញៀន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បង្ក្រាបបាននាពេលកន្លងមក ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ**

៤.១. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ដល់មន្ត្រីអគ្គនាយកដ្ឋានគយនិងរដ្ឋាករ កងរាជអាវុធហត្ថ និងមន្ទីរប្រឆាំងគ្រឿងញៀន ។

៤.២. ត្រៀមសហការជាមួយអង្គការ UNODC រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តធ្វើតេស្តគ្រឿងញៀន និងសារធាតុគីមីផ្សំ ដល់មន្ត្រីអនុវត្តន៍ច្បាប់នៃរាជធានី-ខេត្តចំនួន ១៨ និងមន្ត្រីជំនាញរបស់ក្រសួងពាក់ព័ន្ធ ។

៤.៣. ត្រៀមរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពី ការបិទស្លាកសញ្ញា ការទុកដាក់ ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម (ដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម) ។

៤.៤. បន្តប្រមូលព័ត៌មានពាក់ព័ន្ធនឹងសារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៤.៥. ត្រៀមចូលរួមកិច្ចប្រជុំ លើកទី១ របស់គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ ។

៤.៦. បន្តការរៀបចំកែសម្រួលសមាសភាពក្រុមការងារ និងក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

៥.១. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ០២ រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវិភាគគ្រឿងញៀន ដែលនឹងប្រព្រឹត្តនៅថ្ងៃទី២៥ ខែកក្កដា ដល់ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ នៅប្រទេសថៃ ។

៥.២. ត្រៀមទទួលមន្ត្រីព័ត៌មានវិទ្យា (Information of Technology. IT) របស់ការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីពិភាក្សាក្នុងការរៀបចំបង្កើត Tele-Video Conference នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ។

៥.៣. ត្រៀមចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-វៀតណាម លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅប្រទេសវៀតណាម ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.បគ.៣ ០២ រូប ទៅចូលរួមសិក្ខាសាលាស្តីពីកម្មវិធី UNODC Global SMART Programme Regional ប្រចាំតំបន់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ ២០១៦ នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ ។

៦.២. ត្រៀមពិធីចុះហត្ថលេខាលើគម្រោងត្រួតពិនិត្យកុងតឺន័រ របស់អង្គការ UNODC ។

៦.៣. ត្រៀមចូលរួមកិច្ចប្រជុំ លើកទី២ ស្តីពីផែនការការងាររបស់អាស៊ាន (ASEAN Blue Print) ដើម្បីសន្តិសុខសហគមន៍ប្រឆាំងគ្រឿងញៀនខុសច្បាប់ សម្រាប់ឆ្នាំ២០១៦-២០២៥ ។

៦.៤. ត្រៀមទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន (ASOD) លើកទី៣៧ ស្តីពីបញ្ហាគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៣-២៨ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៦.៥. បន្តសហការជាមួយអង្គការ UNODC ចុះទៅពិនិត្យស្ថានភាពភូមិសាស្ត្រនៅច្រកថ្មដា ស្រុកវាលវែង (ខេត្តពោធិ៍សាត់), ច្រកទ្វារអន្តរជាតិអូរយ៉ាដាវ (ខេត្តរតនគិរី) និង ច្រកអានសេះ (ខេត្តព្រះវិហារ) ដើម្បីពិនិត្យលទ្ធភាពក្នុងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. រៀបចំរបាយការណ៍បូកសរុបលទ្ធផល នៃការចុះពង្រឹងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ០១ បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.២. ត្រៀមរៀបចំកិច្ចប្រជុំពិនិត្យលើផែនការជាតិ ៣ ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៣. ត្រៀមចូលរួមកិច្ចប្រជុំ ពាក់ព័ន្ធនឹងការកែសម្រួលគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៧.៤. បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៥. បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៦. បន្តការរៀបចំសេចក្តីសម្រេចស្តីពីបង្កើតក្រុមការងារ ចុះជួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការកសាងផែនការត្រួតពិនិត្យគ្រឿងញៀនសម្រាប់ថ្នាក់ខណ្ឌ និងសង្កាត់ ។

៧.៧. បន្តជំរុញការរៀបចំសេចក្តីព្រាង សេចក្តីណែនាំស្តីពីការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

៧.៨. បន្តជំរុញការរៀបចំប្រកាសរួម រវាងក្រសួងសុខាភិបាល ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៧.៩. បន្តជំរុញឱ្យរាជធានី-ខេត្ត រៀបចំបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន នៅថ្នាក់ក្រោមខេត្ត (ថ្នាក់ក្រុង ខណ្ឌ ស្រុក សង្កាត់ ឃុំ ភូមិ) ។ ៕

អគ្គលេខាធិការ

នាយឧត្តមសេនីយ៍ មាស_វិរិទ្ធ

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ

" ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីមុខការ "
- ឯកសារ